# Child's Dream

A charity organization supporting children in need

www.childsdream.org



## គោលបំណង

- ដើម្បីជួយលើកស្ទួយ និង បើកឱកាសឱ្យកុមារទទួលបានការអប់រំដែលមានគុណភាពសំរាប់ជាប្រយោជន៏ស្ថិតស្ថេរក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត។
- ដើម្បីជួយផ្គត់ផ្គង់ដល់កុមារ-យុវជននូវសុខភាព និង ជីវភាពរស់នៅប្រចាំថ្ងៃ។
- ដើម្បីជំរុញឱ្យកុមារមានការភ្ញាក់រឭក និង ប្រុងប្រយ័ត្នពីគ្រោះថ្នាក់ដែលបណ្តាលមកពីការលក់ទំនិញខុសច្បាប់នៃសមាជិកគ្រួសារ ឬ សហគមន៏ ព្រមទាំងជួយលើកទឹកចិត្ត និង ទំនុកបម្រុងដល់សិទ្ធកិត្តិយស និង តម្លៃរបស់ខ្លួន។
- ដើម្បីជួយផ្គត់ផ្គង់ និង គាំទ្រដល់កុមារកំព្រាក្រីក្រ កុមារដែលគ្មានឱកាស និង កុមារពនេចរឱ្យមានឱកាស និង អនាគតដ៏ល្អប្រសើរ។
- ដើម្បីគាំទ្រ និង កសាងកុមារឱ្យមានសិទ្ធ-សេរីភាពក្នុងការសំដែងចេញ ជួយលើកទឹកចិត្តឱ្យកុមារយល់ពីគុណតម្លៃ មោទនភាព និង កិត្តិយសរបស់ខ្លួន រួមទាំងជួយបណ្តុះគំនិត ទស្សនៈល្អៗដល់សង្គម។

## ទីកន្លែងទំនាក់ទំនង

ផ្ទះលេខ ១, ផ្លូវម៉ឺនដាមជ្រា, សយ ១, ឃុំឆាងភឿក, ស្រុកមឿង, ខេត្តឈៀងម៉ៃ, ប្រទេសថៃ, ៥០៣០០

www.childsdream.org
info@childsdream.org

## ប្រភពដើម្ន នមូលនិធិ

មូលនិធិសំរេចសុបិនកុមារ (Child's Dream Foundation) ជាអង្គការក្រៅរដ្ឋាភិបាល បានស្ថាបនាឡើងជាផ្លូវការនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ ២០០៣ នៅប្រទេសស្វីស ដោយលោក Daniel Marco Siegfried និង លោក Marc Thomas Jenni ព្រមទាំងក្រុមគ្រួសារ និង មិត្តភក្តិដែលមានចិត្តប្រណិទាន មានសេចក្តីសង្ឃឹម និង មានគោលបំណងដូចគ្នាក្នុងការជួយមនុស្សជាតិ ជាពិសេសកុមារដែលគ្មានឱកាសក្នុងសង្គម ដើម្បីឱ្យពួកគេមានការអភិវឌ្ឍន៏ខ្លួនឯងទៅរកអនាគតដ៏ល្អ។ មូលនិធិបានចុះបញ្ជីនៅប្រទេសថៃនៅ ថ្ងៃទី ៣ ខែវិច្ឆិកា ឆ្នាំ ២០០៥។

## ស្ថានភាពក្នុងក្រុមប្រទេសអនុតំបន់ទនេ្លមេគង្គ

ក្រុមប្រទេសអនុតំបន់ទន្លេមេគង្គ ( **Mekong Sub-Region : MSR)** ជាប្រទេសកំពុងអភិវឌ្ឍន៏ដែលជួបប្រទះនឹងបញ្ហាខុសៗគ្នាដូចជា : បញ្ហាទីផ្សារ ងងឹត (ភូមា, ឡាវ និង កម្ពុជា) ដែលជាបញ្ហាសេដ្ឋកិច្ចខុសពីប្រទេសផ្សេង (ចិន, ថៃ និង វៀតណាម) ដែលមានការចូលទុនគ្នា និង ដាក់ទុនពីបរទេស រួមទាំងបញ្ហាពុករលួយក្នុងប្រទេសផង បញ្ហាការបង្ខំឱ្យផ្លាស់ប្តូរទីលំនៅក្នុងប្រទេសភូមា សភាពការណ៏របស់ជនអម្បូរ និង ជនជាតិភាគតិចផ្សេងៗ បញ្ហាគ្រឿងញៀន និង បញ្ហាផ្សេងៗដែលអាចប្រើលុយទិញបាន។

*“នៅពេលណាដែលមានព្រឹត្តិការណ៏កើតឡើងចំពោះមនុស្សជាតិ កុមារជាអ្នកទទួលរងគ្រោះច្រើនជាងគេ ពួកគេជារឿយៗត្រូវទុកចោលឱ្យរស់នៅដោយខ្លួនឯង ខ្លះត្រូវគេយកទៅលក់ឱ្យឈ្មួញរកកម្រៃពីពលកម្មកុមារ ខ្លះអាចរស់បានដោយការសុំទាន ដែលជារឿងលំបាកក្នុងការជួយកុមារឱ្យរំឭកដល់ការចងចាំរបស់គេ ហើយគេក៏មិនច្បាស់ដែរថា តើមានអ្វីកើតឡើងចំពោះពួកគេនោះ.......”*។

## វិធីដំណើរការ




មូលនិធិបានជួយដល់កុមារដែលខ្វះឱកាសនៅក្នុងប្រទេសអនុតំបន់ទន្លេមេគង្គអស់រយៈពេល ៥ ឆ្នាំ កន្លងមក ក្នុងនោះមានប្រទេស ភូមា ឡាវ កម្ពុជា វៀតណាម និង ថៃ។ ជំនួយភាគច្រើនបានផ្តោតទៅលើវិស័យអប់រំ សេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅ និង ការអភិវឌ្ឍន៏គុណភាពជីវិតរបស់កុមារទាំងនោះ។

..........ការផ្តល់ជំនួយដោយមិនគិតពីជាតិសាសន៏ ពូជពង្ស សាសនា និង ពណ៌សម្បុរ ជាការជួយដោយគ្មានព្រំដែន ដែលត្រូវបានកំណត់ដោយមនុស្សធំ ដូច្នេះយើងបានបើកចំហឱ្យទូលំទូលាយចំពោះកុមារគ្រប់រូប.......

កន្លងមក មូលនិធិបានផ្តល់ជំនួយដល់សហគមន៏ដែលនៅឆ្ងាយដាច់ស្រយាលក្នុងការសាងសង់សាលារៀននៅប្រទេសឡាវ នៅភូមិភាគខាងជើងនៃប្រទេសថៃ រួមទាំងជនដែលបានចាកចោលលំនៅស្ថានពីប្រទេសភូមា ទៅនៅស្រុកម៉ែសត ខេត្តតាក ប្រទេសថៃ, និង ជំនួយវិស័យអប់រំក្នុងជំរំភៀសខ្លួនតាមព្រំប្រទល់ថៃ-ភូមា។

ចំពោះប្រទេសកម្ពុជាវិញ មូលនិធិបានសហការជាមួយអង្គការក្នុងស្រុកគឺ អង្គការខ្មែរអភិវឌ្ឍន៏ខ្មែរ ហៅកាត់ថា "កាកូ " **(Khmer Akphiwat Khmer Organization “KAKO”)** ធ្វើជាសាខារបស់ខ្លួន ក្នុងការអនុវត្តន៏កម្មវិធីអប់រំក្រៅប្រព័ន្ធនៅខេត្តសៀមរាប និង ខេត្តផ្សេងៗ។

នៅប្រទេសវៀតណាម មូលនិធិមិនទាន់មានសកម្មភាពនៅឡើយ គ្រាន់តែបានទំនាក់ទំនងជាមួយរដ្ឋាភិបាល ដើម្បីសុំការអនុញ្ញាតិអនុវត្តការងារតែប៉ុណ្ណោះ។

## ការចូលរួមរបស់លោកអ្នក

លោក-អ្នកអាចជួយឱ្យសុបិនរបស់កុមារសំរេចទៅបាន ដោយការចូលរួមបរិច្ចាគថវិកា ដើម្បីគាំទ្រដល់ការអនុវត្តន៏ការងាររបស់យើង ថវិកាដែលទទួលបាននឹងយកទៅប្រើប្រាស់ក្នុងគម្រោងមូលនិធិ ដើម្បីជាប្រយោជន៏រួមរបស់កុមារ ស្របទៅតាមការប្តេជ្ញាចិត្តរបស់យើង។ ការបរិច្ចាគថវិកាអាចធ្វើបានច្រើនវិធី ដោយការប្រគល់ផ្ទាល់ដៃ, ផ្ទេរតាមធនាគារ, សែក ឬ ប័ណ្ណក្រេឌីត។ លោក-អ្នកអាចមើលពត៏មានលំអិតបន្ថែមតាមគេហទំព័រ www.childsdream.org